សេចក្តីប្រកាសដ៏សំខាន់ សម្រាប់ជនអន្តោប្រវេសន៍

គោលការណ៍ណែនាំថ្មី របស់ក្រសួងអន្តោប្រវេសន៍ (INS) បានអនុញ្ញាតឲ្យ ជនអន្តោប្រវេសន៍ និងកូនរបស់គេទទួលប្រយោជន៍ជំនួយ មិនមែនជាប្រាក់សុទ្ធ និងប្រយោជន៍ជំនួយជាប្រាក់សុទ្ធសំរាប់គោលបំណងពិសេស ដោយ**គ្មាន** ប៉ះពាល់ដល់ស្ថានភាពអន្តោប្រវេសន៍ របស់ពួកគេ មានរួមទាំង៖

- កម្មវិធី Medi-Cal *
- កម្មវិធី Food Stamps
- កម្មវិធី Healthy Families
- ជំនួយផ្នែកពេទ្យនៅពេលមានអាសន្ន
- កម្មវិធី WIC (ស្ត្រី, ទារក និងកុមារ)
- កម្មវិធី ហ្វឹកហ្វឺនការងារ
- ការថែទាំសុខភាពក្នុងស្រុក
- ការធ្វើតេស្ត និងការព្យាបាលរោគឆ្លង
- ផ្តល់ឲ្យជាជំនួយអាសន្ន បានតែម្តង ក្រោមកម្មវិធី CalWORKs
- កម្មវិធីថែទាំសុខភាពនៃស្ត្រីមានគភ៌
- ការថែទាំកូនចិញ្ចឹម និងជំនួយក្នុងការយកក្មេងមកចិញ្ចឹម
- ប្រយោជន៍ជំនួយមិនមែនជាប្រាក់សុទ្ធផ្តល់ឲ្យ ដោយ CalWORKs
- ជំនួយអាសន្ន សំរាប់ពេលមានមហន្តរាយ
- ប័ណ្ណ សំរាប់ប្រើប្រាស់លើការដឹកជញ្ជូន
- សេវាកម្មផ្នែក ថែទាំក្មេង
- ការចាក់ថ្នាំបង្ការរោគ
- កម្មវិធី អាហារមានជីវជាតិល្អ
- ជំនួយខាងផ្ទះសំបែង
- ជំនួយខាងថាមពល
- ជំនួយ ខាងការសិក្សាអប់រំ

*លើកលែងតែ លោកអ្នកប្រើសេវាកម្មនេះសំរាប់បង់ថ្លៃ ការថែទាំយូរអង្វែង(ឧទាហរណ៍, ការថែទាំយូរអង្វែង តាមមន្ទីរថែទាំជនជរា-ពិការ)។

កម្មវិធីខ្លះៗខាងលើ អាចផ្តល់ឲ្យនូវប្រយោជន៍ជំនួយជាប្រាក់សុទ្ធ។ គោលបំណងនៃប្រយោជន៍ជំនួយទាំងនោះគឺមិនមែនជា ប្រាក់ចិញ្ចឹមទេ ប៉ុន្តែដើម្បីជៀសវាងសេចក្តីត្រូវការប្រាក់ជំនួយតទៅទៀត; ហេតុដូច្នេះ ជំនួយទាំងនោះ ពុំមែន គិតជា បន្ទុកសាធារណៈ ទេ។

ការប្រើប្រាស់ប្រយោជន៍ជំនួយទាំងនេះ *នឹងមិន* គិតជា បន្ទុកសាធារណៈ ដោយក្រសួងអន្តោប្រវេសន៍ (INS) ឡើយ។

- ✓ ក្រសួង (INS) *នឹងមិន* បដិសេធ ការអនុញ្ញាតឲ្យចូលស្រុបច្បាប់របស់លោក អ្នកមកកាន់សហរដ្ឋឡើយ។
- ✓ ក្រសួង (INS) *នឹងមិន* បដិសេធការដាក់ពាក្យសុំសំរាប់ការរស់នៅស្រុបច្បាប់ជាអចិន្ត្រៃយ៍របស់លោកអ្នកឡើយ។
- ✓ ក្រសួង (INS) *នឹងមិន* តម្រូវឲ្យលោកអ្នកសងប្រយោជន៍ជំនួយ ដែលលោកអ្នកបានទទួលឡើយ។

សំរាប់ពត៌មានបន្ថែម សូមទូរស័ព្ទ:

WRAP Agency 1-310-337-1550 (ខ្មែរ, ជប៉ុន, លាវ, ថាគ្លាឡុក, វៀតណាម)

Los Angeles County Department of Public Social Services

លេខទូរស័ព្ទ បន្ទុកសាធារណៈ - ភាសាខ្មែរ - (800) 632-9690